# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1423

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងជលផលសមុទ្រ និងតំបន់ឆ្នេរប្រកបដោយចីរភាព

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 01/01/23 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/29 |

៣. ចំណាយគម្រោងសរុប $104,000,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | Fisheries Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលជលផល |

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលក្នុងវាំងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការអភិវឌ្ឍទីផ្សារការងារ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ចូលរួមចំណែកក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃធនធានជលផលឆ្នេរ និងសមុទ្រ
- ស្តារឡើងវិញនូវស្តុកជលផលសមុទ្រ និងបង្កើនផលនេសាទ ដែលនឹងជួយបង្កើនជីវភាពអ្នកនេសាទ និងសេដ្ឋកិច្ចជាតិ
- កែលម្អហេដ្ឋារចនាសម្ព័ន្ធជលផល រួមទាំងទីតាំងឡើងផលនេសាទ និងកន្លែងក្រោយប្រមូលផល ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃ និងសុវត្ថិភាពចំណីអាហារនៃផលិតផលជលផលសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ
- បង្កើនសកម្មភាពវារីវប្បកម្មសមុទ្រ
- ពង្រឹងភាពធន់របស់សហគមន៍មាត់សមុទ្រចំពោះការប្រែប្រួលអាកាសធាតុ ដូចជា ខ្យល់ព្យុះ ការកើនឡើងសីតុណ្ហភាព ការឈ្លានពានអំបិលចូលទៅក្នុងដីកសិកម្ម
- ជំរុញការធ្វើពាណិជ្ជកម្មផល ផលិតផលជលផលសមុទ្រប្រកបដោយចីរភាព

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? មិនគាំទ្រ

១១. វិស័យ ( សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

កសិកម្ម និងការគ្រប់គ្រងដីធ្លី Fisheries

Fisheries

Fisheries

១២. ទីតាំងអនុវត្តគម្រោង ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

កំពត, ព្រះសីហនុ, កោះកុង, កែប,

១៣. គោលបំណងរបស់គម្រោង ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

១-លើកកម្ពស់ផលិតភាព និងភាពធន់នឹងអាកាសធាតុនៃធនធានជលផលតំបន់ឆ្នេរ និងសមុទ្រកម្ពុជា
២-កែលំអហេដ្ឋារចនាសម្ព័ន្ធនៃការឡើងផលនេសាទ ប្រកបដោយគោលការណ៍សុវត្ថិភាពអាហារ យេនឌ័រ និងការគ្រប់គ្រងកំណត់ត្រាផលនេសាទ និងគាំទ្រហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រព័ន្ធវារីវប្បកម្មសមុទ្រដោយដោយមិនប្រើចំណី
៣-ជំរុញការផ្តួចផ្តើមអាជីវកម្ម និងពាណិជ្ជកាវូបនីយកម្មសមុទ្រប្រកបដោយចីរភាពសម្រាប់ផលិតផលជលផលសមុទ្រ

១៤. ការពិពណ៌នាអំពីគម្រោង ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

ក-សមាសភាគទី១ (Output1): ការពង្រឹងលក្ខណៈបន្សាំនៃធនធានជលផលតំបន់ឆ្នេរ និងសមុទ្រ
- ការបង្កើនប្រសិទ្ធភាពចំណាយលើការគ្រប់គ្រង និងល្បាតនៅក្បែរឆ្នេ (ប្រើបច្ចេកវិទ្យា និងមធ្យោបាយដែលមានប្រសិទ្ធភាព
- ការពង្រីកតំបន់គ្រប់គ្រងជលផលសមុទ្រ (MFMA) ឱ្យបាន៣៧%នៃតំបន់ក្បែរឆ្នេរ (inshore area)
- ការដាក់ពង្រាយជម្រកសិប្បនិម្មិតតំបន់ក្បែរឆ្នេរ (៩៧៨០០ ឯកតា)
- ការជំរុញ និងធ្វើទំនើបកម្មវារីវប្បកម្មក្នុងលំហរសមុទ្រដោយមិនប្រើចំណី (open water non-fed maricultre) (3250ហិកតា)
- កម្មវិធីគាំទ្រជីវភាពក្នុងដំណាក់កាល Social economic transition សម្រាប់១០០ក្រុម (Self Help Group-SHGS ក្នុងសហគមន៍គោលដៅ
- ការអនុវត្តកម្មវិធីត្រួតពិនិត្យ និងតាមដានសុវត្ថិភាពអាហារនេសផល ផលិតផលជលផលសមុទ្រ។

ខ- សមាសភាទី២ (Output2) ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតំបន់ឆ្នេរដែលធន់នឹងអាកាសធាតុ
- ការកែលម្អ និងអភិវឌ្ឍន៍ផែនេសាទ (៥-១០ផែ) និងចំណតទូកល្បាត១(អធិការដ្ឋានជលផលសមុទ្រ)
- ការសាងសង់អគារការិយាល័យសម្រាប់ខណ្ឌរដ្ឋបាលជលផល(ខណ្ឌរដ្ឋបាលជលផលកែប និងខណ្ឌរដ្ឋបាលជលផលកំពត)សម្រាប់បម្រើការងារគ្រប់គ្រង និងដំណើរការប្រព័ន្ធបច្ចេកវិទ្យាឌីជីថលក្នុងការត្រួតពិនិត្យ និងល្បាត
- ការសាងសង់អគារការិយាល័យនៃអធិការដ្ឋានសមុទ្រ ជាកន្លែងប្រតិបត្តិការប្រព័ន្ធតាមដាននាវា(VMS)
- ការសាងសង់មជ្ឈមណ្ឌលសហគមន៍ និងអេកូទេសករណ៍នៅតាមបណ្តាសហគមន៍តំបន់ឆ្នេរគោលដៅដែលមានសក្តានុពលទេសចរណ៍។

គ-សមាសភាគទី៣(Output3) ការផ្តួចផ្តើម និងពាណិជ្ជកាវូបនីយកម្មអាជីវកម្មសមុទ្រប្រកបដោយចីរភាព
- ការបង្កើត និងអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យមពាក់ព័ន្ធនឹងផលជលផលសមុទ្រ និងការធ្វើពាណីជ្ជកម្មប្រកបដោយចីរភាព ក្រោមការផ្តួចផ្តើម និងគាំទ្រទាំងផ្នែកបច្ចេកទេសនកងថវិកាពីសហគ្រិនខ្មែរ (Khmer Enterprise-KE)(ចំនួន២៥សហគ្រាស)
- ការចូលរួមរបស់ស្ត្រីក្នុងការចាប់ផ្តើម នឹងការធ្វើអាជីវកម្មពាក់ព័ន្ធនឹងធនធានជលផលសមុទ្រ (២០០នាក់)។

១៥. យុត្តិកម្មលើគម្រោង ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

- គម្រោងនិងការស្តារឡើងវិញនឹងបង្កើនផលិតភាពជលផលសមុទ្រ ជំរុញការអភិវឌ្ឍខ្សែច្រវាក់តម្លៃសមុទ្រ (ទាំងការ នេសាទ និងវារីវប្បកម្មសមុទ្រ) ជានានិរន្តភាពនៃការវិនិយោគ និងជួយដល់រាជរដ្ឋាភិបាលក្នុងការសម្រេចគោលបំណងនៃក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ឆ្នាំ២០១៥-២០២៤ ព្រមទាំងឆ្លើយតបទៅនឹងសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាល(ឆ្នាំ២០១៩)ស្តីពីគោលការណ៍គន្លឹះក្នុងការគ្រប់គ្រងជលផលសមុទ្រ។

**១៦. ផលប្រយោជន៍របស់គម្រោង** (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

- គម្រោងនឹងផ្តល់ប្រយោជន៍ដល់សហគមន៍នេសាទប្រមាណ ២០ ០០០គ្រួសារ និងសហគមន៍តំបន់ឆ្នេរទាំងមូល ប្រមាណ ២០០ ០០០នាក់។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? **មាន**

ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? **ត្រូវបានបញ្ចប់**

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

- **ពង្រឹងការគ្រប់គ្រងធនធានជលផល**
- **ការអភិវឌ្ឍន៍ជីវភាព និងសេដ្ឋកិច្ចជាតិ**
- **រួមចំណែកកាត់បន្ថយភាពក្រីក្រ**
- **ជំរុញការបញ្ជ្រាបយេនឌ័រ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ទាំងពីរ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែល ទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **៣. ការកាត់បន្ថយហានិភ័យ** | 70 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**ការចូលរួមរបស់ស្ត្រីនឹងត្រូវបានលើកកម្ពស់សម្រាប់ការទទួលផលគម្រោង តាមរយៈការផ្តល់សិទ្ធិអំណាចនិងការចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ការផ្តួចផ្តើមអាជីវកម្ម និងការធ្វើពាណិជ្ជកាវូបនីយកម្មនៃជលផលសមុទ្រ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលជលផល មានជំនាញ និងបទពិសោធន៍ក្នុងការអនុវត្តគម្រោង។

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

កិច្ចព្រមព្រៀងហិរញ្ញទានត្រូវបានចុះហត្ថលេខានៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២២ រវាងរាជរដ្ឋាភិបាលជាមួយ ADB nigAFD។ គម្រោងនេះត្រូវបានចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៣ ហើយស្ថិតក្នុងដំណើរការអនុវត្ត។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះនឹងអនុវត្តដោយសហការជាមួយគម្រោងដែលមានស្រាប់ និងដៃគូអភិវឌ្ឍន៍រួមមានEU, FAO, UNIDO, MCC, FFI, WEA ជាដើម។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 2,302.1 | 299.0 | 669.0 | 731.0 | 742.0 | 775.0 | 2,248.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 102.1 | 109.0 | 109.0 | 109.0 | 109.0 | 109.0 | 327.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 1,200.0 | 190.0 | 545.0 | 600.0 | 620.0 | 650.0 | 1,870.0 | 0.0 |
| ផ្សេងៗ | 1,000.0 | 0.0 | 15.0 | 22.0 | 13.0 | 16.0 | 51.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 28,274.9 | 1,416.0 | 7,927.0 | 28,358.0 | 20,261.0 | 11,465.0 | 60,084.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 14,800.0 | 438.0 | 4,268.0 | 9,200.0 | 11,290.0 | 4,085.0 | 24,575.0 | 0.0 |
| សេវាទីប្រឹក្សា | 3,000.0 | 232.0 | 2,740.0 | 8,320.0 | 7,165.0 | 5,800.0 | 21,285.0 | 0.0 |
| ទព្វសម្ភារៈ | 2,100.0 | 746.0 | 684.0 | 6,218.0 | 1,031.0 | 626.0 | 7,875.0 | 0.0 |
| ការបណ្តុះបណ្តាល | 600.0 | 0.0 | 229.0 | 570.0 | 760.0 | 930.0 | 2,260.0 | 0.0 |
| ផ្សេងៗ | 7,774.9 | 0.0 | 6.0 | 4,050.0 | 15.0 | 24.0 | 4,089.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 30,577.0 | 1,715.0 | 8,596.0 | 29,089.0 | 21,003.0 | 12,240.0 | 62,332.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 3,089.0 | 109.0 | 109.0 | 109.0 | 109.0 | 109.0 | 327.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 120.0 | 109.0 | 109.0 | 109.0 | 109.0 | 109.0 | 327.0 | |
| ធនធានផ្សេងៗ | 2,969.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 27,488.0 | 1,606.0 | 8,487.0 | 28,980.0 | 20,894.0 | 12,131.0 | 62,005.0 | |
| | | | | | | | | |
| Asian Development Bank | 11,512.0 | 1,447.0 | 4,285.0 | 10,065.0 | 9,088.0 | 2,306.0 | 21,459.0 | |
| ASEAN Infrastructure Fund | 5,616.0 | 136.0 | 1,058.0 | 2,651.0 | 2,498.0 | 1,578.0 | 6,727.0 | |
| French Development Agency | 4,183.0 | 23.0 | 1,366.0 | 7,475.0 | 3,621.0 | 3,648.0 | 14,744.0 | |
| Other | 6,177.0 | 0.0 | 1,778.0 | 8,789.0 | 5,687.0 | 4,599.0 | 19,075.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 30,577.0 | 1,715.0 | 8,596.0 | 29,089.0 | 21,003.0 | 12,240.0 | 62,332.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: